# សេចក្ដីថ្លែងការណ៍រួម

# សង្គមស៊ីវិលថ្កោលទោសការចាប់ និងឃុំខ្លួនតំណាងសហគមន៍បឹងកក់ទាំងប្រាំពីរនាក់

ថ្ងៃ១២ ខែវិច្ឆិកា ឆ្នាំ២០១៤ - យើងខ្ញុំជាក្រុមសង្គមស៊ីវិល ដែលមានរាយនាមដូចខាងក្រោម មានការសោកស្ដាយជាខ្លាំងចំពោះការចាប់ ឃុំខ្លួន និងផ្ដន្ទាទោសអ្នកតំណាងសហគមន៍បឹងកក់ទាំង ៧នាក់ បន្ទាប់ពីមានការតវ៉ានៅខាងមុខសាលារាជធានីភ្នំពេញ កាលពីព្រឹកម្សិលមិញ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៤។

កាលពីថ្ងៃទី១០ ខែវិច្ឆិកា អ្នកតំណាងសហគមន៍បឹងកក់ទាំង ៧នាក់ ត្រូវបានចាប់ខ្លួន បន្ទាប់ពីបានតវ៉ានៅខាងមុខសាលារាជធានីភ្នំពេញពាក់ព័ន្ធនឹងបញ្ហាលូបង្ហូរទឹកស្អុយដែលជាការទទួលខុសត្រូវរបស់អាជ្ញាធររាជធានីភ្នំពេញ។

តំបន់ដែលនៅក្បែរអតីតបឹងកក់ ត្រូវបានលិចលង់យ៉ាងខ្លាំងដោយទឹកជំនន់ទឹកភ្លៀង បន្ទាប់ពីប្រជាពលរដ្ឋជិត ២០,០០០ នាក់ ត្រូវបានបណ្ដេញចេញដោយបង្ខំឲ្យចេញពីតំបន់នេះនៅឆ្នាំ ២០០៨។ បន្ទាប់ពីមានការផ្ដល់សម្បទាន និងចាក់បំពេញបឹងកក់ដោយក្រុមហ៊ុន ស៊ូកាគូ របស់សមាជិកព្រឹទ្ធសភាមកពីគណបក្សប្រជាជនកម្ពុជា លោក ឡាវ ម៉េងឃីន ទឹកជំនន់នៅក្នុងសហគមន៍កាន់តែមានសភាពអាក្រក់ឡើងៗ ដោយបានធ្វើឲ្យកើនឡើងនូវបញ្ហាសុខភាព និងបង្កឲ្យខូចខាតផ្ទះសម្បែង និងការប្រកបមុខរបរទទួលទាននៅក្នុងបរិវេណសហគមន៍។

អ្នកតំណាងសហគមន៍បឹងកក់ ដែលត្រូវបានចាប់ខ្លួននេះ រួមមាន អ្នកស្រី ង៉ែត ឃុន អ្នកស្រី ទេព វន្នី កញ្ញា សុង ស្រីលាភ អ្នកស្រី គង់ ចន្ថា អ្នកស្រី ផាន់ ឈុនរ៉េត (អ្នកទាំងនេះធ្លាប់ត្រូវបានចាប់ខ្លួន និងផ្ដន្ទាទោសដាក់ពន្ធនាគារកាលពីឆ្នាំ ២០១២ ដោយសារភាពសកម្មនិយមអហិង្សារបស់អ្នកទាំងនោះ) ក៏ដូចជា កញ្ញា ប៊ូ ឆវី និង នង ស្រេង។

លោក អ៊ី សារ៉ុម នាយកប្រតិបត្តិនៃសមាគមធាងត្នោត បានមានប្រសាសន៍ថា៖ “ការចាប់ខ្លួនផ្ដន្ទាទោស និងដាក់ពន្ធនាគារ ទៅលើអ្នកតំណាងសហគមន៍បឹងកក់ មិនបានដោះស្រាយបញ្ហាបានទេផ្ទុយទៅវិញសកម្មភាពនេះនឹងធ្វើឲ្យកើនឡើងនូវការចាប់អារម្មណ៍ និងសាមគ្គីភាពពីមជ្ឈដ្ឋានអន្តរជាតិលើករណីរបស់អ្នកទាំងនោះ”។ លោកបានបន្តទៀតថា៖“រាជរដ្ឋាភិបាលត្រូវ

យល់ថាទុក្ខព្រួយរបស់ប្រជាពលរដ្ឋដែលបានកើតមានឡើងតាមរយៈការតវ៉ាដោយអហិង្សា ត្រូវតែត្រូវបានដោះស្រាយ”។

បន្ទាប់ពីត្រូវបានឃាត់ខ្លួនអស់មួយយប់នៅការិយាល័យនគរបាលចរាចរណ៍ជើងគោករាជធានីភ្នំពេញអ្នកតំណាងទាំង ៧នាក់ ត្រូវបានបញ្ជូនទៅកាន់សាលាដំបូងរាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១១ ខែវិច្ឆិកា ជាកន្លែងដែលអ្នកទាំងនោះត្រូវបានសាកសួរចម្លើយដោយព្រះរាជអាជ្ញា លោក សៀង សុខ។ បន្ទាប់ពីធ្វើការសាកសួរព្រះរាជអាជ្ញាបានសម្រេចចោទប្រកាន់អ្នកទាំងនោះពីបទបង្កឧបសគ្គដល់ចរាចរណ៍សាធារណៈ (មាត្រា ៧៨ នៃច្បាប់ចរាចរណ៍ផ្លូវគោក)។

បន្ទាប់ពីសាកសួររួច ព្រះរាជអាជ្ញា លោក សៀង សុខ បានបញ្ជាឲ្យជនជាប់ចោទចូលខ្លួនក្នុងតុលាការភ្លាមៗដោយមិនមានការស៊ើបអង្កេត។ សវនាការត្រូវបានបើកដោយចៅក្រម លោក ម៉ុង មុន្នី សោភា ដោយចាប់ផ្តើមនៅម៉ោង ៣ និង ៣០នាទី រសៀល ថ្ងៃទី១១ ខែវិច្ឆិកា គឺរយៈពេលតិចជាង ៥ម៉ោង ក្រោយពីអ្នកតំណាងទាំង ៧នាក់ត្រូវបានសាកសួរ និងចោទប្រកាន់ដោយព្រះរាជអាជ្ញា។ ត្រឹមម៉ោង ៦ ល្ងាច អ្នកតំណាងទាំង ៧នាក់ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ១ឆ្នាំ ដែលជាទោសអតិបរមា និងពិន័យជាប្រាក់ចំនួនប្រមាណជា ៥០០ ដុល្លារអាមេរិកក្នុងមួយនាក់ៗ។

ណាលី ពីឡុក នាយិកាអង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ បានមានប្រសាសន៍ថា៖ “ជាថ្មីម្តងទៀត នេះបង្ហាញថាប្រព័ន្ធតុលាការនៅតែបន្តត្រូវបានគេរំលោភបំពាន ដើម្បីគំរាមកំហែងសកម្មជន ដោយមិនមានការទទួលខុសត្រូវពេញលេញ”។ អ្នកនាងបានបន្តទៀតថា៖ “ការចាប់ខ្លួនអ្នកតំណាងទាំង ៧នាក់នេះ គឺជាការព្រួយបារម្ភមួយយ៉ាងខ្លាំងជាពិសេស ៥នាក់ ក្នុងចំណោមអ្នកទាំងនោះ ធ្លាប់ត្រូវបានជាប់ពន្ធនាគារដោយសារភាពសកម្មនិយមដោយអហិង្សាម្តងរួចមកហើយ”។

**<u>គាំទ្រដោយ៖</u>**

*១. សហគមន៍បន្ទាយស្រី (BS)*
*២. សហគមន៍បឹងកក់ (BKL)*
*៣. សហគមន៍បុរីកីឡា (BK)*
*៤. អង្គការអភិវឌ្ឍន៍សម្លេងសហគមន៍ (BCV)*
*៥. សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា (BWTUC)*

*៦. សមាគមមន្ត្រីរាជការកម្ពុជា (CICA)*
*៧. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)*
*៨. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)*
*៩. គណៈកម្មាធិការស្ត្រីកម្ពុជា (CAMBOW)*
*១០. សហព័ន្ធសហជីព កម្មករចំណីអាហារ និងសេវាកម្ម (CFSWF)*
*១១. គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)*
*១២. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)*
*១៣. សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ (CITA)*
*១៤. សហភាពការងារកម្ពុជា (CLC)*
*១៥. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)*
*១៦.គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលដើម្បីលុបបំបាត់រាល់ទម្រង់នៃការសអើងលើស្ត្រីភេទ (NGO-CEDAW)*
*១៧. បណ្តាញយុវជនកម្ពុជា (CYN)*
*១៨. សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (C.CAWDU)*
*១៩. សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC)*
*២០. មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC)*
*២១. បណ្តាញកសាងសន្តិភាព (CPN)*
*២២. អង្គការសមធម៌កម្ពុជា (EC)*
*២៣. សមាគមកសិករដើម្បីសន្តិភាព និងការអភិវឌ្ឍន៍ (FAPD)*
*២៤. អង្គការយេនឌ័រ និងការអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC)*
*២៥. ក្រុមការងារពិសេសសិទ្ធិលំនៅឋាន (HRTF)*
*២៦. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)*
*២៧. គណៈកម្មាធិការអព្យាក្រឹត្យ និងមិនលំអៀងសម្រាប់ការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា (NICFEC)*
*២៨. សមាគមធាងត្នោត (STT)*
*២៩. សហគមន៍ថ្មគោល (TK)*
*៣០. វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា*

**សម្រាប់ពត៌មានបន្ថែម សូមទាក់ទង:**

- លោក ច័ន្ទ ពុទ្ធិស័ក្ត អ្នកតំណាងសហគមន៍បឹងកក់ ទូរស័ព្ទលេខ៖ ០១២ ៩១០ ០២៣

- លោក អំ សំអាត អ្នកសម្របសម្រួលបច្ចេកទេសស៊ើបអង្កេតនៃអង្គការ លីកាដូ ទូរស័ព្ទលេខ៖ ០១២ ៣២៧ ៧៧០
- អ្នកស្រី ឆាយ គីមហ៊ាន អ្នកតំណាងសហាគមន៍បុរីកីឡា ទូរស័ព្ទលេខ៖ ០១៧ ៥២២ ៣០៣